ក្រសួងអប់រំរដ្ឋ NSW

Connecting to nature, culture and your community

Family resources

# ការភ្ជាប់ទៅនឹងធម្មជាតិ វប្បធម៌ និងសហគមន៍របស់អ្នក

## ធនធានសម្រាប់គ្រួសារ



ក្របខ័ណ្ឌការរៀនសូត្រសម្រាប់កុមារតូច (Early Years Learning Framework) គឺជាក្របខ័ណ្ឌជាតិលើការរៀនសូត្រ  ដែលត្រូវបានប្រើនៅក្នុងមត្តេយ្យសាលា និងសេវាកម្មកុមារតូចទាំងអស់។ វាណែនាំការបង្រៀន និងការរៀនសូត្រដោយមានលទ្ធផលនៃការរៀនសូត្រចំនួនប្រាំ ដែលជួយឱ្យកុមារក្លាយជាអ្នករៀនពូកែ និងមានសមត្ថភាព។

លទ្ធផលនៃការរៀនសូត្រទី 2 គឺអំពីកុមារភ្ជាប់ទៅនឹងសហគមន៍របស់ពួកគេ និងពិភពលោកដែលពួកគេរស់នៅ។ កុមាររៀនពីរបៀបទាក់ទង និងធ្វើការជាមួយអ្នកដទៃ ហើយចាប់ផ្តើមយល់ដឹងពីផលប៉ះពាល់នៃសកម្មភាពរបស់ពួកគេផ្ទាល់។ កុមាររៀនអបអរសាទរ និងឱ្យតម្លៃភាពខុសគ្នា ហើយថែរក្សាបរិស្ថាន។

សួករំកមាប់ព័ត៌មានបដែដ ្មអំពី Early Years Learning Framework សូមចូលរៀមីល៖

https://www.education.gov.au/collections/translations-belonging-being-and-becoming-early-years-learning-framework-australia

### សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកមត្តេយ្យសាលា ឬសេវាកម្មសម្រាប់កុមារតូចរបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាផ្ទាល់មាត់ ដើម្បីជួយក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ ប្រតិបត្តិករនឹងហៅលេខទូរស័ព្ទដែលអ្នកផ្តល់ឱ្យ ហើយរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទជូនអ្នក ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។



NSW GOVERNMENT

# ការរៀនសូត្រនៅសាលារៀន

## ការរៀនសូត្រ សម្រាប់កុមារតូច

## ការភ្ជាប់ និងការចូលរួមចំណែក មានន័យថា៖

កុមារដឹងថាពួកគេជាកម្មសិទ្ធិ ហើយអាចចូលរួមដោយការគោរព

កុមារដឹងថាវាមានន័យយ៉ាងដូចម្តេច ដើម្បីឱ្យមានភាពយុត្តិធម៌ដល់អ្នកដទៃ

កុមារយល់ដឹងថាមនុស្សគ្រប់គ្នាខុសគ្នា ប៉ុន្តែអាចធ្វើការរួមគ្នា ដើម្បីធ្វើឱ្យពិភពលោកក្លាយជាកន្លែងដែលប្រសើរជាងមុន

កុមារដឹងពីរបៀបថែរក្សាបរិស្ថាន

សិស្សអាចចែករំលែកវប្បធម៌របស់ពួកគេ និងរៀនអំពីវប្បធម៌ផ្សេងទៀត (មុខវិជ្ជា៖ ភូមិវិទ្យា)

សិស្សមានការគោរព អាចធ្វើការជាមួយអ្នកដទៃ និងប្រព្រឹត្តចំពោះមនុស្សដោយយុត្តិធម៌ (មុខវិជ្ជា៖ ការអប់រំរាងកាយ)

សិស្សប្រើការប្រឌិតញាណរបស់ពួកគេដើម្បីភ្ជាប់ទៅសហគមន៍ និងវប្បធម៌របស់ពួកគេ (មុខវិជ្ជា៖ សិល្បៈច្នៃប្រឌិត)

សិស្សយល់ដឹង ហើយអាចធ្វើការជ្រើសរើសប្រកបដោយនិរន្តរភាព (ផ្នែកមុខវិជ្ជាទាំងអស់)